ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម
ចូល លេខ ១៥៥
ថ្ងៃទី ២១.០៤.២៣
បញ្ជូន........

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៣៦២៦ កសក

# លិខិតបញ្ជូន

**គោរពជូនៈ -ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង**

| ល.រ | រាយមុខលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | -របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំត្រីមាសទី១** និងទិសដៅអនុវត្តបន្ត ............................ | ១ច្បាប់ | "ដើម្បីជូនជ្រាប" --------- |

ថ្ងៃ១២រោច ខែចេត្រ ឆ្នាំថោះ ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២៣

**ត.ប.រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

**ស្រី វុឌ្ឍី**

24.04.23

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងត្រីមាសទី១នេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបានចំនួន ៦៨១ ៨៥៩ហ.ត ស្មើនឹង ១៣៩,៥២% នៃផែនការចំនួន ៤៨៨ ៧០៨ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ និងវិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសទី១នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់ ការប្រជុំពិចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២៣ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចក្នុងឆ្នាំ២០២៣ នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១- លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំង

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៦៨១ ៨៧៦ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៥៨១ហ.ត ស្មើនឹង០,០៩% និងដោយគ្រឿងយន្តចំនួន ៦៨១ ២៩៥ហ.ត ស្មើនឹង៩៩,៩១% លើសឆ្នាំមុន ៤១ ៦៤៤ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ១៣ហ.ត លើសឆ្នាំមុន ៨ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៦៨១ ៨៥៩ហ.ត ស្មើនឹង១៣៩,៥២% នៃផែនការចំនួន ៤៨៨ ៧០៨ហ.ត លើសឆ្នាំមុន ៤២ ៧២១ហ.ត។
- ការប្រមូលផលស្រូវប្រាំងសម្រេចចំនួន ៥៩៤ ៩២៤ហ.ត ទទួលបរិមាណផលសរុបចំនួន ២ ៧៨១ ៧១២តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៦៧៦តោន/ហ.ត។

#### ១.២ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំង

- ដំណាំសាកវប្បកម្មអនុវត្តបានចំនួន ៣៨ ០៣៣ហ.ត ស្មើនឹង១០០,៩៩% នៃផែនការចំនួន ៣៧ ៦៦០ហ.ត លើសឆ្នាំមុន ២ ៤៥៧ហ.ត
- ដំណាំឧស្សាហកម្មអនុវត្តបានចំនួន ១២៣ ៩៨៩ហ.ត ស្មើនឹង១០៥,៤៥% នៃផែនការចំនួន ១១៧ ៥៨០ហ.ត លើសឆ្នាំមុន ១៩ ៥៥៨ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

## ១.៣ ការនាំចេញផលិតផលកសិកម្ម

### ១.៣.១ ការនាំចេញអង្ករ

ការនាំចេញអង្ករក្នុងត្រីមាសទី១ ឆ្នាំ២០២៣ មានចំនួន ១៧៦ ៥៨១តោន ក្នុងនោះ ការនាំចេញអង្ករក្នុងខែមីនា ឆ្នាំ២០២៣ មានចំនួន ៧៩ ១១៤តោន។

អង្ករក្រអូបគ្រប់ប្រភេទមានចំនួន ១៥២ ៣៤៧តោន អង្ករសគ្រប់ប្រភេទមានចំនួន ១៨ ៧៣៩តោន និងអង្ករចំហុយមានចំនួន ៥ ៤៩៥តោន។

បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២០ប្រទេស មានបរិមាណសរុបចំនួន ៥៦ ៣១៣តោន ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ៨៤ ៧៧៣តោន ទិសដៅអាស៊ានចំនួន ២ប្រទេស មានបរិមាណសរុបចំនួន ៩ ៩២០តោន និងទិសដៅដទៃទៀតចំនួន ១៨ប្រទេស មានបរិមាណសរុប ២៥ ៥៧៥តោន។

ក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៤៧ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ១២៤ ៨១៩តោន និងក្រុមហ៊ុន៣៧ដទៃទៀតបាននាំចេញត្រឹមតែ ៥១ ៧៦២តោន។

### ១.៣.២ ការនាំចេញស្រូវ

ការនាំចេញស្រូវក្នុងត្រីមាសទី១ ឆ្នាំ២០២៣ មានចំនួន ១ ៥៦១ ៥១២តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ៨៦០ ៥៥០តោន)។

### ១.៣.៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ មានចំនួន ១ ៥៥៧ ៦០៥,៣៦តោន ក្នុងនោះរួមមាន៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ៨២២ ៧២៨តោន ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ៧២៣ ៧០០តោន ប្រទេសវៀតណាមចំនួន ៩៩ ០០០តោន និងប្រទេសចិនចំនួន ២៨តោន
- ដំឡូងមីស្រស់មានចំនួន ១៥៥ ២១០តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ១៣១ ៧១០តោន និងប្រទេសថៃចំនួន ២៣ ៥០០តោន
- ម្សៅដំឡូងមីមានចំនួន ១៤ ៧០១,៣០តោន ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១៤ ៦៤២តោន ប្រទេសជប៉ុនចំនួន ២៥,៣០តោន ប្រទេសអ៊ីតាលីចំនួន ១៧តោន និងប្រទេសឥណ្ឌាចំនួន ១៧តោន
- កាកសំណល់ដំឡូងមីមានចំនួន ៣៨ ២៥២តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣០ ៥០០តោន ប្រទេសថៃចំនួន ៧ ១០០តោន និងប្រទេសចិនចំនួន ៦៥២តោន
- គ្រាប់ស្វាយចន្ទីមានចំនួន ២១៤ ៤៩៧,៧៦តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ២១២ ៦២០,៥៣តោន ប្រទេសថៃចំនួន ១ ៥៣៦តោន ប្រទេសចិនចំនួន ៣០៦,៨០តោន ប្រទេសជប៉ុនចំនួន ២៨,០៣តោន និងប្រទេសកូរ៉េចំនួន ៦,៤០តោន
- គ្រាប់ពោតមានចំនួន ១៥ ៧០៤,៦១តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ១៤ ៩០០តោន កោះតៃវ៉ាន់ចំនួន ៧៩៥,០៩តោន និងប្រទេសកូរ៉េចំនួន ៩,៥២តោន
- គ្រាប់សណ្តែកបាយមានចំនួន ៤ ២៥០តោន នាំចេញទៅប្រទេសវៀតណាម
- គ្រាប់សណ្តែកសៀងមានចំនួន ៥ ៧០០,០០២តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៥ ៦០០តោន ប្រទេសថៃចំនួន ១០០តោន និងប្រទេសជប៉ុនចំនួន ០,០០២តោន
- ផ្លែចេកស្រស់មានចំនួន ៩៥ ០២៨,៣៨តោន ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៨៨ ៩៤៧,៩២តោន ប្រទេសវៀតណាមចំនួន ៦ ០៦០,៧០តោន និងប្រទេសជប៉ុនចំនួន ១៩,៧៦តោន
- ផ្លែស្វាយស្រស់មានចំនួន ៤៦ ៤៥២,៦៤តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣៦ ៥៩៨,៩៨តោន ប្រទេសថៃចំនួន ៩ ៨២៨,៣០តោន និងប្រទេសកូរ៉េចំនួន ២៥,៣៦តោន

- ដំណាប់ស្វាយមានចំនួន ៦ ៥៩៧,៨៦តោន ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៥ ៩៦៣,៤២តោន ប្រទេសហ្វីលីពីនចំនួន ៣១៩,១៤តោន ប្រទេសថៃចំនួន ១៥៨,៦៩តោន ប្រទេសន័រវែសចំនួន ៧៣,២៦តោន ប្រទេសជប៉ុនចំនួន ៥២,១៦តោន ចក្រភពអង់គ្លេសចំនួន ៨,៥៩តោន ប្រទេសដាណឺម៉ាកចំនួន ៨,៤៦តោន ប្រទេសស៊ុយអ៊ែតចំនួន ៨,៤៦តោន ប្រទេសកូរ៉េ ៥,៤០តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ០,២៥តោន និងសហរដ្ឋអាមេរិក ចំនួន ០,០៣តោន

- ផ្លែមៀនស្រស់មានចំនួន ៣ ៤២២,២៥តោន នាំចេញទៅប្រទេសចិន

- ដូងប្រេងមានចំនួន ២១ ៩៧៥តោន ក្នុងនោះនាំចេញទៅប្រទេសឥណ្ឌាចំនួន ១៨ ៦០០តោន និងប្រទេស ម៉ាឡេស៊ីចំនួន ៣ ៣៧៥តោន

- ម្រេចមានចំនួន ៨២២,៦៥៤តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៧៦៥តោន សហរដ្ឋអាមេរិក ចំនួន ២៦,១៤តោន ប្រទេសកូរ៉េចំនួន ១៦,២០តោន ប្រទេសបារាំងចំនួន ៩,៥៤តោន ប្រទេសប៊ែលហ្ស៊ិក ចំនួន ២,៣៦តោន ប្រទេសជប៉ុនចំនួន ១,៣៨២តោន ប្រទេសឥណ្ឌាចំនួន ០,៩៦តោន ប្រទេសអាល្លឺម៉ង់ចំនួន ០,៩០តោន ប្រទេសសិង្ហបុរីចំនួន ០,១០តោន កោះតៃវ៉ាន់ចំនួន ០,០៤តោន ប្រទេសអូស្រ្តាលីចំនួន ០,០៣តោន និងប្រទេស ម៉ាឡេស៊ីចំនួន ០,០០២តោន

- បន្លែចម្រុះមានចំនួន ៥៩,១៦តោន នាំចេញទៅប្រទេសបារាំង

- និងផលិតផលចំនួន ៥៩មុខ ផ្សេងទៀតមានចំនួន ១១២ ២០៣,៧៤តោន។

**១.៣.៤ ការប៉ាន់ស្មានតម្លៃនៃការនាំចេញកសិផល**

ការប៉ាន់ស្មានតម្លៃគិតជាទឹកប្រាក់ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ដែលទទួលបានពីការនាំចេញកសិផល (ឯកតាតម្លៃផ្អែកតាមវិក្កយបត្ររបស់អ្នកនាំចេញ) មានចំនួន ១ ៣៨៤ ៥៣៤ ៨៥៦,២៨ដុល្លារអាមេរិក ដែលក្នុងនោះ៖

- ការនាំចេញអង្ករមានចំនួន ១៥០ ៩៧៦ ៧៥៥ដុល្លារអាមេរិក
- ការនាំចេញស្រូវមានចំនួន ៣១៣ ៨៦៣ ៩១២ដុល្លារអាមេរិក
- ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ៩១៩ ៦៩៤ ១៨៩,២៨ដុល្លារអាមេរិក។

## ២- ផ្នែកផលិតកម្មកៅស៊ូ

**២.១ ផ្ទៃដីកៅស៊ូ**

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ៥៧៨ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៧ ០២០ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩២ ៤០២ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦៥ ១៥៦ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១៥ ៣៣២ហ.ត ស្មើនឹង៧៨% និងផ្ទៃដីថែទាំចំនួន ៨៩ ២៤៦ហ.ត ស្មើនឹង២២%។

**២.២ ផលិតកម្មកៅស៊ូ**

- ផលិតផលជ័រកៅស៊ូក្នុងរយៈពេល២ខែ ឆ្នាំ២០២៣ មានចំនួន ៥៩ ៥២៩តោន កើនឡើងចំនួន ១០ ៤៩៥តោន ស្មើនឹង២១% ធៀបនឹងរយៈពេល២ខែ ឆ្នាំ២០២២

- ផលិតផលឈើកៅស៊ូក្នុងរយៈពេល២ខែ ឆ្នាំ២០២៣ មានចំនួន ៧៥៥ម$^{៣}$ ។

**២.៣ ការនាំចេញកៅស៊ូ**

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូក្នុងរយៈពេល២ខែ ឆ្នាំ២០២៣ មានចំនួន ៥៨ ៥៩០តោន កើនឡើងចំនួន ១០ ១៨១តោន ស្មើនឹង២១% ធៀបនឹងរយៈពេល២ខែ ឆ្នាំ២០២២

- បរិមាណបញ្ចេញលក់ឈើកៅស៊ូក្នុងរយៈពេល២ខែ ឆ្នាំ២០២៣ មានចំនួន ១ ៣៦១ម$^{៣}$។

**២.៤ តម្លៃកៅស៊ូ**

- តម្លៃលក់ជ័រកៅស៊ូគិតជាមធ្យមក្នុងរយៈពេល២ខែ ឆ្នាំ២០២៣ គឺ១ ៣៤៩ដុល្លារ/តោន ថយចុះចំនួន ២៣៦ដុល្លារ/តោន ស្មើនឹង១៤% ធៀបនឹងរយៈពេល២ខែ ឆ្នាំ២០២២

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារ គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៤ ៥០០៛/គ.ក្រ ដល់ ៥ ០០០៛/គ.ក្រ និងជ័រកក (DRC 50%) មានការប្រែប្រួលពី ២ ០០០៛/គ.ក្រ ដល់ ៣ ១០០៛/គ.ក្រ។

### ២.៥ ចំណូលពីការនាំចេញជ័រកៅស៊ូ និងឈើកៅស៊ូ

- ចំណូលពីការនាំចេញជ័រកៅស៊ូក្នុងរយៈពេល២ខែ ឆ្នាំ២០២៣ មានចំនួន ៧៩ ០៦២ ៤១៤ដុល្លារ
- ចំណូលពីការនាំចេញឈើកៅស៊ូក្នុងរយៈពេល២ខែ ឆ្នាំ២០២៣ មានចំនួន ៣០៧ ២៩៦ដុល្លារ។

## ៣- ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បកស្រាយគម្របព្រៃឈើឆ្នាំ២០២២ និងប្រមូលព័ត៌មាននៅទីវាលជាក់ស្តែងតាមចំណុចនិយាមកាមួយចំនួន ធ្វើការចាត់ថ្នាក់រូចតាមរូបភាពផ្កាយរណប និងមានភាពមិនច្បាស់លាស់ ដើម្បីតាមដាន ការប្រែប្រួលគម្របព្រៃឈើ ឆ្នាំ២០២៣ នៅខេត្តបន្ទាយមានជ័យចំនួន ១៩០ចំណុច
- ចេញសេចក្តីប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ត្រពាំងផ្តៅ និងព្រៃសហគមន៍កំពប់អំបិល មានផ្ទៃដីសរុបទំហំ៤ ៣៧២ហ.ត
- ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ៣សហគមន៍ ព្រៃសហគមន៍ព្រៃខ្លា ព្រៃសហគមន៍ភូមិជ័រម្គាន និងព្រៃសហគមន៍ភូមិអូរអាចម៍កុក មានផ្ទៃដីសរុបទំហំ៧១៤ហ.ត
- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តសរុបចំនួន ៣៩គ្រឿង និងយានយន្តចំនួន ៧២គ្រឿង ជូនក្រុមហ៊ុនចំនួន៤
- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ៣នាក់ មានឈើហ៊ុបមូលចំនួន ៥៤៩ម៣ ឈើជ្រុងចំនួន ១១៨ម៣ កូនឈើចំនួន ១០ ០១៧ដើម អុសចម្រុះចំនួន ៧០ស្ទែរ និងជ័រទឹកចំនួន ៣៩៦តោន។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- ចុះអនុវត្តគម្រោងអភិរក្សសត្វខ្ទីងក្នុងតំបន់សហគមន៍ព្រៃឈើវាលកន្សែង ខេត្តក្រចេះ និងបានដំឡើងម៉ាស៊ីនថតរូបស្វ័យប្រវត្តិចំនួន ៨គ្រឿង ដើម្បីធ្វើការថតចាប់យករូបភាពសកម្មភាពសត្វព្រៃគ្រប់ប្រភេទ និងអង្កេតតាមដានកត្តាគំរាមកំហែងផ្សេងៗដែលកំពុងកើតមាននៅក្នុងតំបន់ព្រៃសហគមន៍
- ចុះសិក្សាស្រាវជ្រាវ និងអង្កេតតាមដានវត្តមានសត្វព្រៃស្ថិតនៅក្នុងតំបន់ភ្នំក្អែ ខេត្តក្រចេះ និងបានដំឡើងម៉ាស៊ីនថតរូបដោយស្វ័យប្រវត្តិចំនួន ៣គ្រឿង ដើម្បីធ្វើការថត និងចាប់យករូបភាពសកម្មភាពសត្វព្រៃគ្រប់ប្រភេទដែលកំពុងមានវត្តមាន និងរស់នៅក្នុងតំបន់ភ្នំក្អែ
- ចុះប្រមូលសំណាករុក្ខជាតិកេសរកូល (អ័រគីដេរព្រៃ) ចំនួន ១លើក នៅក្នុងស្រុកឆែប ខេត្តព្រះវិហារ ដោយប្រមូលសំណាករុក្ខជាតិកេសរកូល (អ័រគីដេរព្រៃ) ចំនួន ៧១សំណាក ដើម្បីកំណត់អត្តសញ្ញាណដែលមានចំនួន ៧អម្បូរ និងប្រមូលសំណាករុក្ខជាតិសំខាន់ៗដូចជាពពួកស្លែសម្រាប់ប្រើប្រាស់ ដើម្បីជួយពន្លឿនការដុះលូតលាស់របស់កេសរកូល (អ័រគីដេរព្រៃ)
- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនចំនួន ៩ច្បាប់ មានស្វាក្ដាមចំនួន ២ ៩៧៤ក្បាល សត្វដំរីស្រុក ១ក្បាល និងសត្វប្រវឹកចំនួន ៧០០ក្បាល និងលិខិតអនុញ្ញាតថែរក្សា ចិញ្ចឹមសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៣០ច្បាប់ សម្រាប់ការថែរក្សាសត្វត្រចៀកកាំចំនួន ២៣ច្បាប់ និងសត្វព្រៃប្រភេទផ្សេងចំនួន ៧ច្បាប់ មានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កណ្តាល និងខេត្តកំពង់ស្ពឺ។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៥មានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៦ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានស្វាក្តាមសរុបចំនួន ១៤៤ ៥៩២ក្បាល ក្នុងនោះ កូនកើតក្នុងខែក្នុងត្រីមាសទី១មានចំនួន ៥ ៣៧៤ក្បាល
- បានកំពុងថែរក្សាសត្វព្រៃចំនួន ១ ៧១៨ក្បាល (បក្សីចំនួន ៥៤ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៥ប្រភេទ)
- សង្គ្រោះសត្វព្រៃថ្មីចំនួន ២១៤ក្បាល ព្យាបាលចំនួន ១០៥ក្បាល និងស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងបានដោះលែងទៅព្រៃធម្មជាតិវិញចំនួន ២០៤ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ២៦នាក់ បានចុះល្បាត នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ១១គីឡូម៉ែត្រ និងអនាម័យព្រៃបាន ០,៨ហ.ត។

### ៣.៤ ការងារដាំដើមឈើ

- ចុះពិនិត្យទីតាំងសមស្របសម្រាប់ត្រៀមរៀបចំប្រារព្ធពិធីរុក្ខទិវា៩ កក្កដា ឆ្នាំ២០២៣ នៅក្នុងខេត្ត កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម និងខេត្តត្បូងឃ្មុំ ក្នុងនោះទីតាំងដីសមស្របស្ថិតនៅស្ថានីយដាំឈើម្សៅក្រដាស ហ៊ុន សែន មានក ក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ៨០៧ហ.ត ក្នុងនោះចម្ការពូជឈើទំហំ១០៤ហ.ត ឡូតិ៍បង្ហាញ កសិ-រុក្ខកម្មទំហំ៣៩ហ.ត ចម្ការឈើដាំទំហំ៦២៤ហ.ត និងចម្ការរុក្ខទិវា៩កក្កដា សរុបទំហំ៤០ហ.ត ស្ថិតក្នុងខេត្តកំពត ព្រះសីហនុ កំពង់ធំ កំពង់ឆ្នាំង បាត់ដំបង ក្រចេះ និងខេត្តព្រះវិហារ

- បណ្តុះកូនឈើចម្រុះប្រភេទចំនួន ៥៨ ៩៨០ដើម ក្នុងនោះមានថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌ រដ្ឋបាលព្រៃឈើនៅទូទាំងប្រទេសចំនួន ១ ៥០០ដើម និងថ្នាលបណ្តុះកូនឈើទាំង៥ ចំនួន ៥៧ ៤៨០ដើម

- ឈូសឆាយ និងសម្អាតដីសម្រាប់ដាំឈើទំហំ១ ៦៤៦ហ.ត ដីចម្ការអាកាស្យាទំហំ៤០០ហ.ត និងបណ្តុះ កូនប្រេងខ្យល់ចំនួន ២០០ ០០០ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុម អន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ១០៧ករណី ក្នុងនោះ សំណុំរឿងបទល្មើស ព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ៦០ករណី និងសំណុំរឿងបទល្មើសព្រៃឈើបញ្ជូនទៅតុលាការចំនួន ៤៧ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើបានចាប់ឃាត់ និងដកហូតរួមមាន៖ ឈើមូលចំនួន ០,៨៩ម$^{3}$ ឈើអារចំនួន ១២៥ម$^{3}$ វត្ថុតាងសត្វព្រៃចាប់ឃាត់មានសត្វព្រៃចម្រុះចំនួន ២៤៤ក្បាល និងសាច់សត្វព្រៃទម្ងន់ ៩២គ.ក្រ ផ្ទៃដីព្រៃឈើ កាប់រានទំហំ ៥៣៨ហ.ត អនុផលព្រៃឈើ ព្រមទាំងឧបករណ៍សម្ភារផ្សេងៗមួយចំនួនទៀត

- វត្ថុតាងសត្វព្រៃ និងសំណាកសត្វព្រៃពុំមានចងក្រងសំណុំរឿង រួមមាន៖ ប្រគល់-ទទួលចំនួន ១៥៤ករណី (តាមរយៈប្រគល់-ទទួលចំនួន ១២៣ករណី ធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពចំនួន ១០ករណី និងដកហូត លែង និង បំផ្លាញចោលចំនួន ២១ករណី រួមមាន៖ សត្វព្រៃរស់ចម្រុះប្រភេទចំនួន ៣៩៣ក្បាល សត្វព្រៃងាប់ចម្រុះប្រភេទ ចំនួន ២ ៥០៤ក្បាល និងសំណាក ៤១,៩៤គ.ក្រ។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំពន្យាររោងម៉ាស៊ីន និងរោងសិប្បកម្មចំនួន ៣កន្លែង ស្ថិតនៅរាជធានីភ្នំពេញ ខេត្ត មណ្ឌលគិរី និងខេត្តបាត់ដំបង

- ចុះពិនិត្យសំណើសុំពន្យាររោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូល តែមួយ) ចំនួន ៥កន្លែង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តព្រៃវែង កណ្តាល ស្វាយរៀង និងខេត្តកំពង់ស្ពឺ

- ក្រុមហ៊ុនចំនួន៣នាំចេញផលិតផលរានទេវតាទៅក្រៅប្រទេសចំនួន ៩៦ម$^{3}$ និងជ័រទឹកចំនួន ៣៩តោន

- ក្រុមហ៊ុនចំនួន២នាំចូលឈើកែច្នៃមានចំនួន ២៦២ម$^{3}$

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន២មានគ្រឿងសង្ហារិមឫស្សីកែច្នៃចំនួន ៦តោន និងជ័រទឹក ចំនួន ១៦តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន១មានឈើកែច្នៃសរុបចំនួន ៥០ម$^{3}$។

### ៣.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីវិស័យព្រៃឈើសរុបចំនួន ៥៨១ ៦៣៧ ០៨៨រៀល និង ៧៧ ៦៦១,១៧ដុល្លារ។

## ៤- ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ

### ៤.១ ការងារផលិតកម្មសត្វ

បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្តៈ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។ ចុះពិនិត្យ និងវាយតម្លៃទីតាំងស្នើសុំបង្កើតកសិដ្ឋានចិញ្ចឹមជ្រូកពូជ ជ្រូកសាច់ មាន់សាច់ មាន់យកស៊ុត មាន់ពូជ ស្វា គោ និងសេះ ជាប្រភេទកសិដ្ឋានខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ បានចំនួន១៥កសិកដ្ឋាននៅខេត្តសៀមរាប កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ចាម និងខេត្តកំពត ដែលកសិដ្ឋាននីមួយៗមានឡជីវឧស្ម័ន។

### ៤.២ ការងារសុខភាពសត្វ

#### ៤.២.១ លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ

ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វសរុបបានចំនួន ៨៨ករណី ក្នុងនោះ បង្ក្រាបបទល្មើសបាន៥ករណី។ រាជធានី-ខេត្តចំនួន២៥បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៤៩ ២៨៦លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

#### ៤.២.២ ការងារផ្សព្វផ្សាយបច្ចេកទេស

- ចុះឃោសនាផ្សព្វផ្សាយស្តីពីជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៥
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន១។

#### ៤.២.៣ ការងារនីតិកម្ម និងវិវាទ

- កំពុងប្រជុំពិភាក្សាលើព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈបសុពេទ្យ
- កំពុងប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន និងការធ្វើអាជីវកម្មពិឃាតសត្វ
- កំពុងប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋាន បច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ
- កំពុងប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌតម្រូវលម្អិតសម្រាប់បង្កើតសត្តឃាតដ្ឋានប្រភេទ "ក" និង "ខ" ទីតាំង និងបទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន
- ចុះប្រជុំផ្សព្វផ្សាយច្បាប់ និងកម្រងលិខិតបទដ្ឋានគតិយុត្តវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅខេត្តបាត់ដំបង
- ចុះពិនិត្យតាមដានការអនុវត្តច្បាប់វិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្តចំនួន៤។

### ៤.៣ ការងារស្រាវជ្រាវ

#### ៤.៣.១ ការងារស្រាវជ្រាវផលិតកម្ម

បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១៣១ក្បាល។

#### ៤.៣.២ ការងារស្រាវជ្រាវសុខភាពសត្វ

ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ៣ ២៨៦វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) និងជំងឺដុំពកស្បែកគោ ក្របី

(LSD)។ វត្ថុវិភាគចំនួន ១៩មានប្រភពមកពីភូមិរលាំង ឃុំរលេច ស្រុកស៊ីធកណ្ដាល ខេត្តព្រៃវែង ភូមិព្រែកស្វាយ ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង និងពីទួលព័ន្ធតាឡី បឹងស្នោហ៍ភូមិទ័ពស្ដេច ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង វិជ្ជមាន AI (H5N1)។ វត្ថុវិភាគចំនួន ១០មានប្រភពមកពីសត្តឃាតដ្ឋាន និងសាច់ក្លាស្សេ សង្កាត់បឹងទំពុន ពីភូមិ អូរអាម ឃុំស្រែខ្ទម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ពីភូមិសំរោង ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប និងមកពីទីតាំង J និង P ភ្នំពេញ វិជ្ជមានជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។ វត្ថុវិភាគចំនួន ៥មានប្រភពមកពីភូមិពពាល ឃុំពពាល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ភូមិព្រៃបឹស ឃុំត្នោតស្រុកកំពង់រោង ខេត្តស្វាយរៀង និងមកពីភូមិព្រៃហៀរ ឃុំគោកពោធិ៍ ស្រុកបុរីជលសារ ខេត្តតាកែវ វិជ្ជមានជំងឺដុំពកស្បែកគោក្របី (LSDV)។

## ៥- ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីសម្រេចបានចំនួន ៨៦០តោន ស្មើនឹង៨,៦០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀប ត្រីមាសទី១ ឆ្នាំ២០២២ កើនឡើងចំនួន ២១០តោន
- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ៥២ ១០០តោន ស្មើនឹង១៧,៣៧% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២២ កើនឡើងចំនួន ១២ ១០០តោន
- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៦ ០០០តោន ស្មើនឹង៤,២៩% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២២ ថយចុះចំនួន ៣ ៣០០តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៤៤ ៧៤០តោន ស្មើនឹង៣៤,៤២% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀប ត្រីមាសទី១ ឆ្នាំ២០២២ កើនឡើងចំនួន ១៨ ៦៤០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៨៦ ០០០តោន ស្មើនឹង២៣,៨៩% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២២ កើនឡើងចំនួន ១ ០០០តោន
- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៧៤ ៩០០ក្បាល ស្មើនឹង២៤,៩៧% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២២ ថយចុះចំនួន ១ ៤០០ក្បាល
- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៤៤ ៥០០ ០០០កូន ស្មើនឹង១៤,៨៣% នៃផែនការចំនួន ៣០០ ០០០ ០០០កូន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២២ ថយចុះចំនួនប្រមាណ ៣ ០០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ១២ ៨០០តោន ស្មើនឹង២១,៣៣% នៃផែនការចំនួន ៦០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២២ ថយចុះចំនួន ៨០០តោន
- ផលនេសាទសមុទ្រអនុវត្តបានចំនួន ២ ៦២០តោន ស្មើនឹង២៦,២០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២២ ថយចុះចំនួន ១១០តោន
- ការផលិតទឹកត្រីអនុវត្តបានចំនួន ១២ ១០០ ០០០លីត្រ ស្មើនឹង២៤,២០% នៃផែនការចំនួន ៥០ ០០០ ០០០លីត្រ ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២២ កើនឡើងចំនួន ៦០០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ៤៨២ករណី ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២២ កើនឡើង ចំនួន ៨៦ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៤៥៣ករណី និងសមុទ្រចំនួន ២៩ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ១៥២តោន ស្មើនឹង២,១៧% នៃផែនការចំនួន ៧ ០០០តោន ប្រៀប ធៀបត្រីមាសទី១ ឆ្នាំ២០២២ ថយចុះចំនួន ២៦៣តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ១៤០តោន ស្មើនឹង១៤% នៃផែនការចំនួន ១ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២២ កើនឡើងចំនួន ៩៩តោន។

**៥.៦ ការប្រមូលថវិកា**

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ១៥៨ ៥៧៧ ៤៨៨រៀល ស្មើនឹង៤២,៨០% នៃផែនការចំនួន ៣៧០ ៥០០ ០០០រៀល ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២២ ថយចុះចំនួន ១២ ១១០ ៣៨៧រៀល។

## ៦- ផ្នែកអន្តរាធិការដ្ឋាន

- ស្រាវជ្រាវព័ត៌មានតាមបណ្ដាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៧៣ករណី លើវិស័យព្រៃឈើ ២៥ករណី ជលផល២០ករណី សុខភាពសត្វនិងផលិតកម្មសត្វ៥ករណី កៅស៊ូ១ករណី ក្សេត្រសាស្ត្រ១ករណី និងវិស័យផ្សេងៗ២១ករណី

- ចូលរួមប្រជុំចំនួន ៨លើក និងចូលរួមពិធីផ្សេងៗ១លើក។

## ៧- ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ២ ៨៩៥ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ១ ២២២ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ១ ២០០ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៤៧៣ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៣ ០៤៤ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរចំនួន ១២១ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៣២ច្បាប់

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំ ដើម្បីក្ដាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការងារសន្តិសុខសណ្ដាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨- ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៨៧៥នាក់ (ស្រី១ ៤៦៧នាក់ ស្មើនឹង២៤,៩៧%) រួមមាន៖
  + អង្គភាពថ្នាក់កណ្ដាលចំនួន ២ ៩៧៦នាក់ (ស្រី៨៦៥នាក់ ស្មើនឹង២៩,០៦%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៨៩៩នាក់ (ស្រី៦០២នាក់ ស្មើនឹង២០,៧៦%)

- រៀបចំប្រកាសស្ដីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ១០នាក់

- រៀបចំប្រកាសស្ដីពីការលុបឈ្មោះមន្ត្រីរាជការចំនួន ៦នាក់ (ទទួលមរណភាពចំនួន ៥នាក់ និងលាឈប់ពីការងារចំនួន ១នាក់)

- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកជូនមន្ត្រីរាជការសរុបចំនួន ៣០នាក់

- រៀបចំសំណើសុំផលិតប័ណ្ណ ប.ស.ស ជូនមន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ១៥៨ប័ណ្ណ និងបានទទួលប័ណ្ណ ប.ស.ស ចំនួន ៧២ប័ណ្ណពីអគ្គនាយកដ្ឋានបេឡាជាតិរបបសន្តិសុខសង្គម

- រៀបចំសំណើសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់កិត្តិយសប្រចាំឆ្នាំ២០២៣ ចំនួន ២ ៥៨៤នាក់

- ការងារបណ្ដុះបណ្ដាលក្នុង និងក្រៅប្រទេសសរុបចំនួន ៣៩៣នាក់ (ស្រី១១៣នាក់) ក្នុងនោះ៖
  + ការបណ្ដុះបណ្ដាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន ៣៨១នាក់ (ស្រី១០១នាក់)
  + ការបណ្ដុះបណ្ដាលក្រៅប្រទេសចំនួន ១២នាក់ (ស្រី៤នាក់)។

## ៩- ផ្នែកផែនការ និងស្ថិតិ

- ធ្វើរបាយការណ៍សង្ខេប និងសូចនាករសំខាន់ៗជាសមិទ្ធផលរយៈពេល៥ឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា
- រៀបចំបូកសរុបសូចនាករសមិទ្ធកម្ម និងគោលដៅនៃគម្រោងថវិកាកម្មវិធីឆ្នាំ២០២៣
- ចុះប្រមូលព័ត៌មានស្តីពីស្ថានភាពវិស័យកសិកម្ម ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២៤-២០២៨ នៅខេត្តកំពង់ធំ សៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ
- ធ្វើរបាយការណ៍លទ្ធផលនៃការចូលរួមសិក្ខាសាលា ដើម្បីណែនាំពីការរៀបចំធាតុចូលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០២៤-២០២៨
- ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្នូលស្តីពីការប្រមូលទិន្នន័យជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ នៅក្រសួងផែនការ
- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍៣ដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងសប្តាហ៍រៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទាំង២៥
- ចុះបេសកកម្មពិនិត្យ និងតាមដានការចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិកម្មនៅខេត្តកំពង់ស្ពឺ កោះកុង កែប ព្រះសីហនុ ក្រចេះ មណ្ឌលគិរី បាត់ដំបង ប៉ៃលិន ព្រៃវែង ស្វាយរៀង ព្រះវិហារ និងខេត្តឧត្តរមានជ័យ
- ចុះពិនិត្យលទ្ធផលការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២២ និងផ្សព្វផ្សាយទិសដៅសម្រាប់អនុវត្តឆ្នាំ២០២៣ រួមមាន៖ ខេត្តព្រះវិហារ សៀមរាប និងខេត្តស្ទឹងត្រែង
- ចុះត្រួតពិនិត្យបឋមវាយតម្លៃផលប៉ះពាល់បរិស្ថាន សង្គម និងបំពេញឯកសារកាតព្វកិច្ចផ្លូវច្បាប់ (Duc Diligence Form) សម្រាប់សំណើពពិធកម្មកសិកម្ម DPL និងរៀបចំឯកសារបរិច្ចាគដីនៅខេត្តបាត់ដំបង ព្រះវិហារ និងខេត្តក្រចេះ
- ចុះប្រមូលព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្មនៅខេត្តតាកែវ និងខេត្តកំពត។

## ១០- ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) សរុបទឹកប្រាក់ចំនួន ២ ៥៤៨ លានរៀល ស្មើនឹង៦,៤៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៣
- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ២៤ ២៨១លានរៀល ស្មើនឹង១៤,៧៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៣
- រៀបចំសំណើសុំអនុញ្ញាតនាំចូលដោយការបង់ពន្ធៈ និងអាករជាបន្ទុករបស់រដ្ឋនូវរថយន្តចំនួន ៣គ្រឿង សម្រាប់ប្រើប្រាស់ក្នុងគម្រោងការគាំទ្រមជ្ឈមណ្ឌលកសិកម្មនៅខេត្តក្រចេះ
- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ៦ក្រុមហ៊ុន
- រៀបចំលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ៤៧ក្រុមហ៊ុន
- ចូលរួមចុះត្រួតពិនិត្យ និងវាយតម្លៃប្រគល់ទទួល ស្តីពីការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតាមបណ្តាសហគមន៍កសិកម្មចំនួន ៧ស្ថិតក្នុងខេត្តកណ្តាល ត្បូងឃ្មុំ កំពង់ធំ និងខេត្តសៀមរាបក្នុងឆ្នាំ២០២២
- ចូលរួមពិនិត្យ និងផ្ទៀងផ្ទាត់តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋសម្រាប់ឆ្នាំ២០២២ របស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចជា៖ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ អគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកដ្ឋានកៅស៊ូ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល សាកលវិទ្យាល័យភូមិន្ទកសិកម្ម មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស នាយកដ្ឋាននីតិកម្មកសិកម្ម អគ្គាធិការដ្ឋាន នាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ នាយកដ្ឋានកសិ-ឧស្សាហកម្ម និងនាយកដ្ឋានផែនការ និងស្ថិតិ។

## ១១- ផ្នែកសវនកម្មផ្ទៃក្នុង

- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ
- រៀបចំបូកសរុបរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ
- រៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះក្នុងឆ្នាំ២០២២
- រៀបចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស ឆ្នាំ២០២៣
- ចុះធ្វើសវនកម្មចំនួន ១៩សវនដ្ឋាន ស្មើនឹង២៤,៣៩% នៃផែនការ៤១សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន ៤៤អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥៦,០៦% នៃផែនការចំនួន ៥៨%។

## ១២- ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- សម្របសម្រួលអនុវត្តគម្រោងស្តីពីការកសាងសមត្ថភាពរបស់សមាជិកនៃប្រទេសតាមដងទន្លេមេគង្គ ដើម្បីការពារសត្វផ្សោតទឹកសាប និងជីវចម្រុះ
- សម្របសម្រួលឆ្លើយតបស្តីពីការរៀបចំគម្រោងស្នើសុំហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលកូរ៉េសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០២៥
- សម្របសម្រួលជាមួយអង្គភាពជំនាញលើការរៀបចំសំណើសុំសិទ្ធិប្រទាន ដើម្បីចុះហត្ថលេខាលើពិធីសារស្តីពីលក្ខខណ្ឌតម្រូវចត្តាឡីស័ក និងអនាម័យសម្រាប់នាំចេញវាវីសត្វរស់ពីព្រះរាជាណាចក្រកម្ពុជាទៅប្រទេសចិន
- សម្របសម្រួលរៀបចំកិច្ចប្រជុំ និងលិខិតឆ្លើយតបសំណើរបស់ប្រទេសរុស្ស៊ី ស្នើកម្ពុជាប្រឆាំងទៅនឹងសំណើរបស់ប្រទេសស្វីស អូស្ត្រាលី និងម៉ាលី ពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មលើអនុសញ្ញារ៉ូថឺដាម
- សម្របសម្រួលសំណើសុំអនុញ្ញាតនាំចូលអង្ករជាជំនួយរបស់ប្រទេសជប៉ុនចំនួន ៣០០តោន ស្មើនឹង ១០ ០០០បាវ តាមច្រកកំពង់ផែស្វយ័តក្រុងព្រះសីហនុទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សម្របសម្រួលលើសំណើពិនិត្យផ្តល់យោបល់ និងធាតុចូលលើសេចក្តីព្រាងឯកសារទស្សនទានស្តីពីការបង្កើតក្របខណ្ឌសេដ្ឋកិច្ចពណ៌ខៀវអាស៊ាន និងសំណើសុំផ្តល់យោបល់ ឬបន្ថែមធាតុចូលលើសេចក្តីព្រាងឧបសម្ព័ន្ធនៃផែនការសកម្មភាពអាស៊ាន សហរដ្ឋអាមេរិកសម្រាប់ឆ្នាំ២០២១-២០២៥ ទៅក្រសួងពាណិជ្ជកម្ម
- ចុះពិនិត្យទីតាំងត្រៀមរៀបចំ និងប្រារព្ធទិវាពិភពលោក ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី និងគ្រោះរាំងស្ងួត UNCCD ឆ្នាំ២០២៣។

## ១៣- ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦១ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៨២ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម ជីកសិកម្មចំនួន ២១ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្មចំនួន ១៨ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ៨ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ២៧ក្រុមហ៊ុន សរុបចំនួន ១៩៨សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- ពិនិត្យ និងផ្តល់មតិលើសំណើសុំគោលការណ៍ផ្សព្វផ្សាយធ្វើសិក្ខាសាលាបណ្តុះបណ្តាលដល់អាជីវករលក់សម្ភារកសិកម្ម និងកសិករ អំពីរបៀបប្រើប្រាស់ផលិតផលថ្នាំកសិកម្ម និងជីកសិកម្មប្រកបដោយសុវត្ថិភាពខ្ពស់តាមរយៈការធ្វើស្រែបង្ហាញ ស្ថានីយវិទ្យុ និងទូរទស្សន៍នៅតាមបណ្តារាជធានី-ខេត្ត ជូនក្រុមហ៊ុនចំនួន៣។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យក្រុមហ៊ុនប្រកាសប្រតិវេទន៍នាំចូលថ្នាំកសិកម្ម ជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ

ដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣៣ក្រុមហ៊ុន

- ចុះត្រួតពិនិត្យវាយតម្លៃឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្ម និងចុះត្រួតពិនិត្យវាយតម្លៃ ប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ៣៤ក្រុមហ៊ុន។

## ១៤- ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- តាមដាន និងដកស្រង់ព័ត៌មានពាក់ព័ន្ធនឹងវិស័យកសិកម្មពីប្រព័ន្ធផ្សព្វផ្សាយនានាក្នុងព្រះរាជាណាចក្រកម្ពុជាសរុបចំនួន ៨៦៩ព័ត៌មាន

- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ និងតាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- ប្រមូលទិន្នន័យ និងរៀបចំផែនទីដំណាំតាមសហគមន៍កសិកម្មរបស់សហគមន៍ពន្លកថ្មី ក្នុងស្រុកកងមាស ខេត្តកំពង់ចាម ស្ថិតនៅក្នុងភូមិសាស្ត្រឃុំចំនួន ២គឺឃុំរកាគយ និងឃុំព្រែកក្របៅ បានដាំដុះដំណាំសំខាន់ៗដូចជាៈ ស្រូវ បន្លែ និងស្វាយកែវរមៀត ដំណាំមួយចំនួនទៀតដូចជា ចេក ដូង និងឪឡឹក

- បណ្ណាល័យកសិកម្មទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តី ដែលទទួលបានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ៦៣ក្បាល/ច្បាប់។

## ១៥- ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្តីពីបច្ចេកទេសចិញ្ចឹមបង្កងភ្ញាស់កូនបង្កងលក់ បច្ចេកទេសចិញ្ចឹមមាន់ ភ្ញាស់កូនមាន់លក់ និងការដាំដុះបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់

- បានចុះទៅថត Video បទយកការណ៍ចំនួន ១ប្រធានបទ
- បានធ្វើការផលិត Video និងចាក់ផ្សាយឡើងវិញចំនួន ២ប្រធានបទ
- បានផលិត Video នាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ
- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៦ដើម្បីចាក់ផ្សាយ។

## ១៦- ផ្នែកកសិ-ឧស្សាហកម្ម

- អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មចំនួន ៨កិច្ចសន្យា រួមមានៈ ខេត្តឧត្តរមានជ័យ២កិច្ចសន្យា កំពង់ឆ្នាំង ១កិច្ចសន្យា និងខេត្តបន្ទាយមានជ័យ៥កិច្ចសន្យា

- ចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូចទៅទីផ្សារ តាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តឧត្តរមានជ័យ

- ចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តរតនគិរី

- ចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសក្រោយប្រមូលនៃផលិតផលកសិកម្មនៅខេត្តពោធិ៍សាត់

- ចុះបណ្តុះបណ្តាលកសិករស្តីពីការលើកកម្ពស់ស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្មនៅខេត្តមណ្ឌលគិរី

- រៀបចំសំណាកប្រហុកចំនួន ៦ប្រភេទ ដើម្បីវិភាគបាក់តេរីបង្កគ្រោះថ្នាក់មានដូចជា សាល់ម៉ូណេឡា អ៊ីកូឡាយ ពពួកផ្សិត បាក់តេរីសរុប និងអ៊ិនធីរ៉ូបាក់ទែរីហ្សេស

- រៀបចំសំណាកម្សៅត្រី ដើម្បីវិភាគ អាហ្លាតុកស៊ីន និងលោហៈធ្ងន់ (អាសេនិច បារត កាដ្យូម និងសំណ)។

## ១៧- ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បន្តការអភិរក្សពូជដំណាំនៅក្នុងវិទ្យាស្ថានចំនួន ៣៩ប្រភេទ រួមមានៈ ស្រូវចំនួន ៦ ៧៧៦បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣៨ប្រភេទ សរុបចំនួន ២ ៦៤៨បញ្ជីក/សំណាក សរុបទាំងអស់ចំនួន ៩ ៤២៤បញ្ជីក/សំណាក។ ប្រមូលប្រភេទពូជដំណាំថ្មីៗបន្ថែមទៀតបានចំនួន ៦ប្រភេទ សរុបចំនួន ៦៤សំណាក (ត្រសក់៣៧សំណាក ល្ពៅ ១៤សំណាក ឪឡឹក១សំណាក ត្រប់១សំណាក ត្រឡាច១០សំណាក និងពោត១សំណាក) ដាំវាយតម្លៃ និងកំណត់

លក្ខណៈពូជដំណាំចំនួន ៤មុខ រួមមាន៖ មេឡុង៥០សំណាក ម្ទេស១៦សំណាក ល្ពៅ១៤សំណាក និងសណ្តែកព្រៃ ២៤សំណាក សរុបចំនួន ១០៤សំណាក

- ធ្វើពិសោធន៍ចំនួន ៣៤ប្រភេទ នៅ៧១កន្លែង ក្នុងនោះ មានស្រែបង្ហាញចំនួន ៣២កន្លែង

- ក្នុងរយៈពេលមួយត្រីមាស ឆ្នាំ២០២៣នេះ មានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ២១៧ ៩៨០នាក់ ដោយគិតជាមធ្យមមានប្រមាណ២ ៤២២នាក់/ថ្ងៃ។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២៣ សរុបចំនួន ៣ ១៤៤នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- មហាវិទ្យាល័យទាំងអស់បានរៀបចំពិធីការពារសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- ចុះអនុស្សរណៈយោគយល់ (MOU) រវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងក្រុមហ៊ុន ស៊ី ជេ ធី ធី ត្រេឌីង ស្តីពីការបើកវគ្គបណ្តុះបណ្តាលភាសាជប៉ុន និងផ្តល់ឱកាសការងារនៅប្រទេសជប៉ុន

- ធ្វើបទបង្ហាញអំពីការផលិតជីសរីរាង្គ និងផលិតផលផ្សេងៗដោយប្រើប្រាស់បច្ចេកវិទ្យាផលិតកម្មគ្មានកាកសំណល់ (Zero Waste Agriculture Technology)

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបង្កាត់គោសិប្បនិម្មិត ដោយសហការជាមួយក្រុមហ៊ុន BP CATTLE BREED។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២៣ សរុបចំនួន ១ ៦៩៨នាក់ (ស្រី៦២៩នាក់) លើជំនាញ៖ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូ ដើម្បីជាប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងមន្ត្រីដោយការសិក្សាស្រាវជ្រាវផ្តោតលើ៖ ត្រី បង្កង បង្គា មាន់ ទា ពពែ ក្របី គោទឹកដោះ បន្លែ ផ្កា ឫស្សី ស្រូវ ចេក ស្វាយចន្ទី កាកាវ វ៉ានីឡា ស្តៅ អាហារ ថ្នាំសត្វល្អិត និងជី

- សហប្រតិបត្តិការសំខាន់ៗរួមមានការបណ្តុះជាលិការុក្ខជាតិ អាក្វាពោនិក (ប្រព័ន្ធវារីវប្បកម្ម) ការកែច្នៃស្វាយចន្ទី ការផលិតម្សៅឫស្សី ការចិញ្ចឹមគោទឹកដោះ ការពិសោធដំណាំជប៉ុន និងការសរសេរសៀវភៅសម្រាប់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថាន។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២៣ សរុបចំនួន ៥០៤នាក់ (ស្រី១៧០នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើការចម្រាញ់ប្រេងរុក្ខជាតិដូចជា ស្លឹកគ្រៃ ស្លឹកក្រូចសើច និងម្រេច

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- តាមដាន ស្រង់ និងវិភាគទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូសរុបចំនួន ៦២ពិសោធន៍

- ថែទាំកូនកៅស៊ូ Tissue Culture Plant ចំនួន ២ ៥០០កូន ទទួលមកពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន (RRI-CATAS)

- ត្រួតពិនិត្យទូទៅការការពារ និងថែទាំចម្ការពិសោធន៍ក្លូនកូនកៅស៊ូស៊ីដលីង និងច្បារបង្កាត់ពូជ

- ស្រង់ទិន្នន័យជំងឺ Oidium នៅចម្ការពិសោធន៍ក្លូននៅក្នុងស្ថានីយសរុបចំនួន ១១ចម្ការពិសោធន៍

- វាស់ទំហំដើមកៅស៊ូនៅចម្ការពិសោធន៍ក្លូនសរុបចំនួន ១១ចម្ការពិសោធន៍ (IR.AA.06 ដល់ IR.AA.12 GSET.02, SSCT.01, PV.AA.01 និង PV.AA.02)

- ចុះជ្រើសរើសទីតាំងសម្រាប់រៀបចំចម្ការបង្ហាញអំពីការអនុវត្តន៍កសិកម្មល្អលើបច្ចេកទេសប្រមូលផលទឹកជ័រនៃចម្ការគ្រួសារនៅស្រុកកែវសីមា ខេត្តមណ្ឌលគិរី ដោយមានកិច្ចសហការជាមួយអគ្គនាយកដ្ឋានកៅស៊ូ និងអង្គការ WWF-Cambodia

- បានរៀបចំ និងបោះពុម្ពផ្សព្វផ្សាយនូវអត្ថបទបច្ចេកទេសស្តីពីអនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០២៣-២០២៥

- រៀបចំលាយសូលុយស្យុងវត្ថុធាតុគីមី និងវិភាគរកស្តង់ដារសរីរទឹកជ័រ (Latex diagnosis-LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (R-SH)

- ពិភាក្សារៀបចំពិធីសារពិសោធន៍ និងកំណត់ទីតាំងដើម្បីបង្កើតចម្ការពិសោធន៍អំពីប្រព័ន្ធចង្វាក់ចៀររង្វើល d3, d4, d5 និង d6 នៅក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខេត្តក្រចេះ d4, d6, d8 និង d10 នៅចម្ការកៅស៊ូ Coviphama ខេត្តមណ្ឌលគិរី

- អនុវត្តការបំប៉ៅកូនកៅស៊ូសម្រាប់ត្រៀមដាំដុះថ្មី និងដាំជួស

- រៀបចំថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០២៣-២០២៤ និងរៀបចំដីសម្រាប់ត្រៀមដាំដុះកូនកៅស៊ូឆ្នាំ២០២៣

- រៀបចំឯកសារការងារមន្ទីរពិសោធន៍ជាតិយថាប្រភេទឱ្យត្រូវតាមបទដ្ឋានស្តង់ដារសម្រាប់ត្រៀមស្នើសុំ ISO/IEC 17025: 2017

- ចុះត្រួតពិនិត្យ វាយតម្លៃរោងចក្រ និងមន្ទីរពិសោធន៍របស់ក្រុមហ៊ុនចំនួន ៣ដែលបានស្នើសុំបន្តសុពលភាពបញ្ជិការោងចក្រ និងមន្ទីរពិសោធន៍ឡើងវិញ

- ចូលរួមធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ជាមួយសមាគមកៅស៊ូអន្តរជាតិ (International Rubber Association) (IRA) លើកទី១២៨។

## III- សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបានចំនួន ៦៨១ ៨៥៩ហ.ត ស្មើនឹង១៣៩,៥២% នៃផែនការចំនួន ៤៨៨ ៧០៨ហ.ត និងការប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ៥៩៤ ៩២៤ហ.ត ទទួលបរិមាណផលសរុបចំនួន ២ ៧៨១ ៧១២តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៦៧៦តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសមាសភាពចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំ

រួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។

ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១- ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្ម

- បន្តពង្រឹងការងារត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិ និងតាមតម្រូវការនៃប្រទេសនាំចូល ក្នុងគោលបំណងជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា

- ស្រាវជ្រាវឯកសារបច្ចេកទេស និងរៀបចំជាសៀវភៅបច្ចេកទេសស្តីពីស្តង់ដារពូជដំណាំនៃប្រភេទពូជដំណាំអទិភាពដូចជាជំឡូងមី ស្វាយចន្ទី ម្រេច មៀនប៉ៃលិន ទុរេន និងដំណាំបន្លែ

- ស្រាវជ្រាវឯកសារបច្ចេកទេស និងរៀបចំជាសៀវភៅបច្ចេកទេសស្តីពីពិធីសារពិសោធន៍វាយតម្លៃសម្តែងកម្មនៃពូជដំណាំនៅទីវាលដើម្បីធ្វើអាជីវកម្ម ពិសោធន៍វាយតម្លៃ DUS និង VCU សម្រាប់ប្រភេទដំណាំជាអទិភាពដូចជាស្រូវ ពោត ជំឡូងមី សណ្តែកបាយ ស្វាយ ស្វាយចន្ទី ម្រេច និងដំណាំបន្លែ

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២- ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តបណ្តុះបណ្តាលបច្ចេកទេសពិឃាតសត្វប្រកបដោយមនុស្សធម៌ដល់មន្ត្រីបសុពេទ្យ និងអាជីវករពិឃាតសត្វ

- ត្រៀមលក្ខណៈចុះអនុវត្តវិធានការបសុព្យាបាលកន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្ដាសាយបក្សី (H5N1) ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ជំងឺដុំពកស្បែកគោ ក្របី (LSD) និងជំងឺឆ្លងសត្វផ្សេងៗ

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ។

### ៣- ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្ដុះផ្ទត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្ដុះបណ្ដាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្ដីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្ដីជូនដំណឹង លេខ១៣៤៨ សជណ.កធ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្ដារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្ដុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

### ៤- ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្ដីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្ដីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការសហគមន៍នេសាទគ្មានបទល្មើសជលផល។

### ៥- ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្ដាអង្គភាពក្រោមឱវាទនិងបណ្ដាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់ សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិ ឱ្យបានសមស្របតាមនីតិវិធី

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃព្រហ ៥ រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**